ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានរតនាគារជាតិ
នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ

# សូមគោរពជូន
# ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

## I-<u>លទ្ធផលការងារដែលបានអនុវត្តក្នុងខែតុលា ឆ្នាំ២០១៦÷</u>

អគ្គនាយកដ្ឋានរតនាគារជាតិបានអនុវត្តការងារក្នុងខែតុលាឆ្នាំ២០១៦ មួយចំនួនដូចខាងក្រោម÷

១-បានបន្តជំរុញលើការបើកផ្តល់ប្រាក់បៀវត្សជូនមន្រ្តីរាជការ កងកម្លាំងប្រដាប់អាវុធ របបសន្តិសុខសង្គមរបស់និវត្តជន(បជស) និងបេឡាជាតិអតីតយុទ្ធជន(បជអ) បានទាន់ពេលវេលា។

២-បានបន្តសាកល្បងអនុវត្តការទូទាត់ចំណាយតាមរយៈប្រព័ន្ធ FMIS និងប្រព័ន្ធរបស់ NBC ដើម្បីឈានដល់ដំណាក់កាលទូទាត់តាម E-Transfer ក្នុងប្រព័ន្ធ FMIS Production។

៣-សេចក្តីណែនាំស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាត្រូវបានពិនិត្យនិងចុះហត្ថលេខាដោយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានរតនាគារជាតិ។

៤-បានបន្តសហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារបច្ចេកទេសផ្សេងៗ ជាពិសេសពិនិត្យពិភាក្សានិងជំរុញតាមដានលើការងាររៀបចំរបាយការណ៍ និងដំណើរការមួយចំនួននៃប្រព័ន្ធ FMIS ដើម្បីគាំទ្រដល់ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

៥-បានចូលរួមកិច្ចប្រជុំស្តីពីសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។

៦-បានបន្តរៀបចំនិងធ្វើបច្ចុប្បន្នភាពបន្ថែមលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ និងបានពិនិត្យសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦ ដើម្បីបញ្ជូនទៅសុំការពិនិត្យនិងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ។

៧-បានចូលរួមធ្វើបទបង្ហាញ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់ថវិកាកម្មវិធីក្នុងវគ្គបណ្តុះបណ្តាលស្តីពី "ការរៀបចំថវិកានិងនីតិវិធីអនុវត្តថវិកាកម្មវិធី" ជូនដល់ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត ដែលតួអង្គពាក់ព័ន្ធក្នុងការត្រួតពិនិត្យការអនុវត្តថវិកាកម្មវិធី។

៨-បានបន្តប្រជុំណែនាំនិងបណ្តុះបណ្តាលមន្ត្រីជំនាញទទួលបន្ទុកពិនិត្យការអនុវត្តចំណាយថវិកា ស្តីពីលិខិតបទដ្ឋានគតិយុត្តដែលបានធ្វើបច្ចុប្បន្នភាពថ្មីៗ និងចំណុចសំខាន់ៗពាក់ព័ន្ធនឹងការត្រួតពិនិត្យការចំណាយថវិកាតាមប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធភាពក្នុងការត្រួតពិនិត្យអាណត្តិបើកប្រាក់ និងលិខិតយុត្តិការចំណាយ ដើម្បីទូទាត់ចំណាយថវិកាឱ្យបានទាន់ពេលវេលា និងបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។

៩-បានបន្តណែនាំនិងជំរុញក្រសួង ស្ថាប័នថវិកាកម្មវិធី ជាពិសេសអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ និងអង្គភាពថវិកាដែលទទួលការប្រគល់សិទ្ធិលើកញ្ចប់រជ្ជទេយ្យបុរេប្រទាន ដែលបានអនុវត្តសកម្មភាពចំណាយរួចហើយ ឱ្យប្រញាប់ប្រមូលសក្ខីបត្រចំណាយ ដើម្បីបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់បំពេញបេឡារជ្ជទេយ្យបុរេ-ប្រទានឱ្យបានទាន់ពេលវេលា។

១០-បានចូលរួមប្រជុំពិភាក្សាលើកទី៣ ដើម្បីសម្រួលមាតិកាថវិកា និងប្លង់គណនេយ្យសម្រាប់ថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

១១-បានចូលរួមកិច្ចប្រជុំកញ្ចប់ក្របខណ្ឌ ផែនការសកម្មភាពដំណាក់កាលទី៣ (២០១៧-២០២០) នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (CAP3)។

១២-បានបន្តសហការជាមួយអាជ្ញាធរសវនកម្មជាតិ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្នុងការធ្វើសវនកម្មលើការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

១៣-បានរៀបចំសេចក្តីណែនាំបិទបញ្ជីថវិការដ្ឋបាលថ្នាក់ជាតិនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៦ និងទិសដៅត្រូវអនុវត្តនៅឆ្នាំ២០១៧។

១៤-បានចូលរួមធ្វើបទបង្ហាញស្តីកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យបុរេ ប្រទាន នៅសណ្ឋាគារភ្នំពេញ ។

១៥-បានចូលរួមប្រជុំពិភាក្សាពិរកនីតិវិធីនៃការទូទាត់ប្រាក់លើគម្រោងវិនិយោគថែទាំស្តារ និងអភិវឌ្ឍន៍ហេដ្ឋា រចនាសម្ព័ន្ធប្រព័ន្ធបំភ្លឺសាធារណៈនៅរាជធានីភ្នំពេញ។

១៦-បានបញ្ជូនសេចក្តីព្រាងនៃគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលទៅក្រុមការងារកែទម្រង់គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យ។

១៧-បានបញ្ជូនសេចក្តីព្រាងប្រកាស ស្តីពីរជ្ជទេយ្យបុរេប្រទាននិងរជ្ជទេយ្យករចំណូល សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ទៅក្រុមការងារកែទម្រង់គ្រឹះស្ថានសាធារណៈរដ្ឋបាល របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យ។

១៨-បានរៀបចំប្រជុំអន្តរអគ្គនាយកដ្ឋាន ដោះស្រាយនិងពិនិត្យលើខ្លឹមសារនៃកិច្ចសន្យារបស់សាលារាជធានីភ្នំពេញ និងក្រុមហ៊ុនភ្នំពេញ អភិវឌ្ឍន៍វិស្វកម្ម និងសំណង់។

១៩-បានចូលរួមប្រជុំពិនិត្យសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

២០-បានរៀបចំលិខិតទៅអគ្គនាយកដ្ឋានពន្ធដារ ស្នើសុំការសម្របសម្រួលឱ្យសាខាពន្ធដាររាជធានី ខេត្តទទួលចំណូលពន្ធតាមរយៈអាណត្តិបើកប្រាក់។

២១-បានរៀបចំសេចក្តីព្រាងលិខិតក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើសុំជំរុញគ្រឹះស្ថានសាធារណៈរដ្ឋបាលបើកគណនីប្រាក់បញ្ញើនៅរតនាគារ។

២២-បានរៀបចំ និងបញ្ជូនស្ថិតិសមតុល្យថវិកា SIDA សល់ជូនដៃគូអភិវឌ្ឍន៍ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

២៣-បានចូលរួមប្រជុំពិនិត្យកែសម្រួលមាតិកាថវិកាលើប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣។

២៤-បានបញ្ជូនមន្ត្រីជំនាញពាក់ព័ន្ធ ជួបពិភាក្សាជាមួយក្រុមការងារមូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីទទួលបានធាតុចូលបន្ថែមលើការសិក្សាវិភាគ និងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីពាក់ព័ន្ធលើក្របខណ្ឌគតិយុត្តិព្រមទាំងហានិភ័យថវិកាដែលអាចកើតចេញពីគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជនកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ។

២៥-បានបញ្ជូនមន្ត្រីចូលរួមកិច្ចប្រជុំស្តីពីផែនការសកម្មភាព និងថវិកាសម្រាប់គាំទ្រដល់ការអនុវត្តសាកល្បង ការផ្ទេរមុខងារសេវាអនាម័យជនបទដល់រដ្ឋបាលស្រុកគោលដៅ កាលពីថ្ងៃទី២៦-២៨ ខែតុលា ឆ្នាំ២០១៦ នៅសណ្ឋាគារ Moon Julie ខេត្តព្រះសីហនុ។

២៦-អធិការកិច្ចរតនាគារបានចុះពិនិត្យកិច្ចបញ្ជិកាគណនេយ្យការិយបរិច្ឆេទ២០១៥ និងបណ្តាឆ្នាំពាក់ព័ន្ធនៅរតនាគារខេត្តក្រចេះ រតនាគារខេត្តស្ទឹងត្រែង រតនាគារខេត្តព្រៃវែង និងរតនាគារខេត្តស្វាយរៀង។

**II-ទិសដៅសម្រាប់អនុវត្តការងារខែវិច្ឆិកា ឆ្នាំ២០១៦÷**

អគ្គនាយកដ្ឋានរតនាគារជាតិមានទិសដៅសម្រាប់អនុវត្តការងារខែវិច្ឆិកា ឆ្នាំ២០១៦មានដូចខាងក្រោម÷

១-ត្រូវបន្តជំរុញលើការបើកផ្តល់ប្រាក់បៀវត្ស ជូនមន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធឱ្យបានទាន់ក្នុងខែ។

២-ត្រូវបន្តសហការជាមួយក្រសួង ស្ថាប័នថវិកាកម្មវិធីក្នុងការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តចំណាយថវិកា ជាពិសេសណែនាំ និងជំរុញការអនុវត្តចំណាយរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធី ក្នុងឆ្នាំថវិកា ២០១៦ ឱ្យមានដំណើរការរលូន និងបានត្រឹមត្រូវស្របតាមនីតិវិធីហិរញ្ញវត្ថុ។

៣-ត្រូវបន្តរៀបចំឯកសារផ្សេងៗដើម្បីគាំទ្រការងារសេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ នៅស្ថាប័ននីតិបញ្ញត្តិ។

៤-ត្រៀមចូលរួមប្រជុំពិភាក្សាលើការបើកប្រាក់ឧបត្ថម្ភសម្រាប់សិស្សមន្ត្រី កម្មសិក្សាការី និងសាស្ត្រាចារ្យនៃសាលាភូមិន្ទរដ្ឋបាល។

៥-ត្រៀមចូលរួមធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំថវិកានិងនីតិវិធីអនុវត្តថវិកាកម្មវិធីជូនដល់ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៅថ្នាក់កណ្តាល ដែលជាតួអង្គពាក់ព័ន្ធក្នុងការត្រួតពិនិត្យការអនុវត្តថវិកាកម្មវិធី។

៦-ត្រៀមចូលរួមធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាលផ្ទៃក្នុង ស្តីពីការងារហិរញ្ញវត្ថុនិងថវិកាសម្រាប់លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ។

៧-ត្រូវរៀបចំកិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន ដើម្បីពិនិត្យលើសេចក្តីណែនាំបិទបញ្ជីការិយបរិច្ឆេទឆ្នាំ២០១៦ និងទិសដៅអនុវត្តឆ្នាំ២០១៧។

៨-ត្រូវបញ្ជូនសេចក្តីព្រាងប្រកាសស្តីពីរដ្ឋទេយ្យបុរេប្រទាន ប្រកាសស្តីពីរដ្ឋទេយ្យចំណូល និងប្រកាសស្តីពីគោលការណ៍ណែនាំស្តីពីគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន និងគណនេយ្យរដ្ឋទេយ្យចំណូល របស់ EPA ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៩-ត្រូវរៀបចំលិខិតក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើទៅធនាគារជាតិនៃកម្ពុជា ដើម្បីបើកគណនីចរន្តជាប្រាក់រៀល និងគណនីចរន្តជាប្រាក់ដុល្លារអាមេរិក សម្រាប់គ្រប់គ្រងចំណូល ចំណាយប្រាក់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

១០-អធិការកិច្ចរតនាគារ ត្រូវចុះត្រួតពិនិត្យការងាររបស់រតនាគាររាជធានី ខេត្តជាបន្តបន្ទាប់ទៀត។

១១-គណៈកម្មការជម្រះចោលឯកសារអស់សុពលភាពប្រើប្រាស់ ត្រូវបន្តចុះដុតកម្ទេចឯកសារឆ្នាំ២០០៥ នៅតាមបណ្តារតនាគារខេត្តជាបន្តទៀត។